**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

លេខ ០១៦ សហវ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ឱ្យដំណើរការសន្ទានកម្មរវាង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) សម្រាប់ចំណូលថវិការដ្ឋបាលរាជធានី-ខេត្ត

យោងតាមសេចក្តីជូនដំណឹងលេខ ០០៩ សហវ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ ស្តីពី “ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដំណាក់កាលទី២ ជំហានទី១ នៅរដ្ឋបាលរាជធានី-ខេត្ត”, សេចក្តីណែនាំលេខ ០០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ ស្តីពី “ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធអេហ្វអឹមអាយអេស (FMIS) នៅរដ្ឋបាលរាជធានី-ខេត្ត និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាលសម្រាប់ឆ្នាំ២០២២” ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំរួចរាល់នូវបច្ចេកទេសនៃការធ្វើសន្ទានកម្មរវាងប្រព័ន្ធ FMIS និង ប្រព័ន្ធ NRMIS សម្រាប់ទិន្នន័យចំណូលថវិការដ្ឋបាលរាជធានី-ខេត្ត ដែលជាចំណូលមិនមែនសារពើពន្ធ ។

ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជូនដំណឹងដល់រដ្ឋបាលរាជធានី-ខេត្ត និង អង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលកំពុងប្រើប្រាស់ប្រព័ន្ធ FMIS ទាំងអស់ ជ្រាបថា ចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០២២ នេះតទៅ, ប្រព័ន្ធ FMIS នឹងធ្វើសន្ទានកម្មបន្ថែមជាមួយប្រព័ន្ធ NRMIS ទៅលើចំណូលថវិការបស់រដ្ឋបាលរាជធានី-ខេត្ត ហេតុនេះ រដ្ឋបាលរាជធានី-ខេត្តមិនត្រូវបង្កើតប្រតិបត្តិការចំណូលថវិកានៅក្នុងប្រព័ន្ធ FMIS ទៀតឡើយសម្រាប់ប្រតិបត្តិការចំណូលថវិកាដែលបានបង្កើតក្នុងប្រព័ន្ធ NRMIS រួចរាល់ ដោយប្រតិបត្តិការទាំងនោះនឹងបញ្ជូនទៅក្នុងប្រព័ន្ធ FMIS នៅរៀងរាល់ចុងថ្ងៃនីមួយៗដោយស្វ័យប្រវត្តិ ។ សម្រាប់រតនាគាររាជធានី-ខេត្ត គឺត្រូវបន្តត្រួតពិនិត្យ និង បញ្ចប់ប្រតិបត្តិការចំណូលថវិកាដែលបានពីសន្ទានកម្មខាងលើនេះ ដូចការអនុវត្តសព្វថ្ងៃ ។ ក្នុងករណី រតនាគាររាជធានី-ខេត្ត ពិនិត្យឃើញថាមានកំហុស រតនាគាររាជធានី-ខេត្ត ត្រូវជូនដំណឹងទៅរដ្ឋបាលរាជធានី-ខេត្ត អំពីកំហុស និង ចំណុចដែលត្រូវកែតម្រូវ ដើម្បីកែតម្រូវប្រតិបត្តិការឡើងវិញនៅក្នុងប្រព័ន្ធ NRMIS ដើម្បីធានាបាននូវសង្គតិភាពទិន្នន័យរវាងប្រព័ន្ធ NRMIS និង ប្រព័ន្ធ FMIS ។

រដ្ឋបាលរាជធានី-ខេត្ត និង អង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានបញ្ជាក់ក្នុងសេចក្តីជូនដំណឹង ត្រូវអនុវត្តតាមសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០២២ តទៅ ។

ថ្ងៃ សុក្រ ១១រោច ខែ អស្សុជ ឆ្នាំ ខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

*ចម្លងជូន÷*

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  “ដើម្បីជូនជ្រាប”
- រដ្ឋបាលរាជធានី-ខេត្ត
- រតនាគាររាជធានី-ខេត្ត
  “ដើម្បីអនុវត្ត”
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា

St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA

ទូរសព្ទ:(+៨៥៥) ២៣ ៨៩០ ៦៦៦

Phone : (+855) 23 890 666